អត្ថបទសរសេរតាមអាន៖ ប្រាសាទព្រះវិហារ

ប្រាសាទព្រះវិហារ ឋិតនៅយ៉ាងខ្ពស់ត្រដែត លើកំពូលរាបស្មើនៃជួរភ្នំដងរែក ក្នុងខេត្តព្រះវិហារ។ ប្រាសាទនេះបានសាងសង់ឡើងនៅចុងសតវត្សរ៍ទី៩ ប្រកបដោយក្បូរក្បាច់រចនាដ៏ប្រណីត។ នៅថ្ងៃទី ៧ ខែ កក្កដា ឆ្នាំ២០០៨ ប្រជាជនទូទាំងប្រទេសមានទឹកមុខសប្បាយរីករាយឥតឧបមា។ ក្រោមការ ខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាលកម្ពុជា ប្រាសាទព្រះវិហារដែលជាកេរមរតករបស់ខ្មែរ ត្រូវបានអង្គការយូនីស្កូយល់ព្រមដាក់បញ្ចូលក្នុងបញ្ជីសម្បត្តិបេតិកភណ្ឌពិភពលោក។

ក្នុងថ្ងៃដដែលនោះគ្រប់ក្រសួងមន្ទីរសាលារៀន ប្រមូលផ្តុំគ្នានៅដងទង់ជាតិដើម្បីច្រៀងចម្រៀងជាតិនិងបង្ហូតទង់ជាតិហើយស្តាប់សាររបស់ប្រមុខដឹកនាំរាជរដ្ឋាភិបាល។ឯទីវត្តអារាម ព្រះសង្ឃទូងស្គរនិងសូត្រជយតុប្រសិទ្ធពរជ័យក្នុងឱកាសនោះដែរ។ អំណឹះតទៅ យើងត្រូវតែប្តេជ្ញាការពារសម្បត្តិ បេតិកភណ្ឌពិភពលោកឱ្យបានឋិតថេរចីរកាលជានិរន្តរ៍។